គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ.០៥៤ គជអប/គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី.១១. ខែ.មីនា ឆ្នាំ២០១១..

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**សូមជម្រាបជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ:** ការរៀបចំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ការបង្កើត និងវិធានអនុវត្តមូលនិធិក្រុង ស្រុក ដើម្បីផ្ទេរធនធានសមស្របដល់រដ្ឋបាលក្រុង ស្រុក។

**យោង:** - ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- កិច្ចព្រមព្រៀងស្ដីពីការផ្ដល់ហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលស៊ុយអ៊ែត

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានជាប់ឆ្នោតបានចូលបំពេញមុខងាររបស់ខ្លួនអស់រយៈពេលជាង២ឆ្នាំរួចមកហើយ។ ដោយឡែករចនាសម្ព័ន្ធរដ្ឋបាលរបស់ក្រុមប្រឹក្សាទាំងនោះ ក៏ត្រូវបានរៀបចំនឹងកំពុងត្រូវបានពង្រឹងសមត្ថភាពជាបណ្ដើរៗ សមស្របតាមទស្សនៈវិស័យនៃកម្មវិធីជាតិរយៈ១០ឆ្នាំ(២០១០-២០១៩) សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្តរយៈពេល៣ឆ្នាំ (២០១១-២០១៣) នៃកម្មវិធីជាតិ(ផអ៣)។

បច្ចុប្បន្ននេះ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កំពុងដំណើរការរៀបចំបញ្ចប់នូវផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរបស់ខ្លួន ដើម្បីធានាបាននូវការផ្ដល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ក្នុងន័យឆ្លើយតបចំពោះតម្រូវការជាក់ស្ដែងរបស់មូលដ្ឋាន និងចូលរួមចំណែកដល់ការសម្រេចបាននូវយុទ្ធសាស្ត្រនៃការអភិវឌ្ឍជាតិ។

ផ្អែកតាមបទពិសោធន៍នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរយៈពេលជិត១០ឆ្នាំនៅថ្នាក់ឃុំ សង្កាត់កន្លងមកនេះ បានបង្ហាញឱ្យឃើញពីប្រសិទ្ធភាព និងភាពស័ក្ដសិទ្ធនៃការចាត់ចែងប្រើប្រាស់របស់ឃុំ សង្កាត់ទៅលើថវិកាដែលរដ្ឋបានវិភាជន៍ទៅឱ្យសម្រាប់ការវិនិយោគទៅលើផ្នែកអភិវឌ្ឍមូលដ្ឋាន ដែលបានរួមចំណែក និងជះឥទ្ធិពលយ៉ាងធំធេងដល់ការកាត់បន្ថយភាពក្រីក្រ។ ការអនុវត្តគម្រោងខ្នាតតូចៗទាំងនេះបានផ្ដោត និងផ្ដល់ផលប្រយោជន៍ជាសំខាន់ដល់ប្រជាពលរដ្ឋក្រីក្រ ដែលរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់

បន្ថយនូវគម្លាតរវាងអ្នកមាន និងអ្នកក្រ។ លើសពីនេះ ការអនុវត្តគម្រោងខ្នាតតូចដែលមានចំនួនយ៉ាងច្រើននៅតាមភូមិ ឃុំបានបង្កលក្ខណៈឱ្យមានការចូលរួមយ៉ាងសកម្មពីផ្នែកឯកជនដូចជា អ្នកទទួលការ សហគ្រាសខ្នាតតូច អ្នករកស៊ីតូចតាចនៅមូលដ្ឋាន និងបានបង្កើតការងារយ៉ាងច្រើនដល់ប្រជាពលរដ្ឋ ដែលទាំងនេះ គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញ និងលើកកម្ពស់សេដ្ឋកិច្ចនៅមូលដ្ឋាន។ យោងតាមការវិវត្តន៍ដូចបានរៀបរាប់ខាងលើនេះ និងអាស្រ័យដោយមានការតម្រង់ទិសដូចមានចែងក្នុងច្បាប់រៀបចំអង្គការ ព្រមទាំងកម្មវិធីជាតិរយៈពេល១០ឆ្នាំ និងផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូងស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប បានឯកភាពក្នុងការផ្តោតការយកចិត្តទុកដាក់ចំពោះមុខ ជាពិសេសទៅលើការអភិវឌ្ឍសមត្ថភាពមនុស្ស និងសមត្ថភាពស្ថាប័នរបស់**ថ្នាក់ស្រុក ក្រុង** ដែលត្រូវបានវាយតម្លៃ និងទទួលស្គាល់ថា ជាថ្នាក់រដ្ឋបាលដែលមានតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងការពង្រឹងអភិបាលកិច្ចមូលដ្ឋានក្នុងបែបផែននៃកិច្ចសហការ និងការគាំទ្រផ្នែកបច្ចេកទេសដល់ឃុំ សង្កាត់។

ក្នុងនាមជារដ្ឋបាលដែលមានស្វ័យភាព និងមានការទទួលខុសត្រូវក្នុងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះតម្រូវការខុសៗគ្នានៅមូលដ្ឋានរបស់ខ្លួន ក្រុង ស្រុកចាំបាច់ត្រូវបានផ្តល់នូវធនធានពីថ្នាក់ជាតិសម្រាប់ការអភិវឌ្ឍមូលដ្ឋានក្រោមការសម្រេចចិត្តរបស់ខ្លួនក្នុងកម្រិតណាមួយ ដែលមានលក្ខណៈសមស្របទៅនឹងការចាប់ផ្តើមរៀបចំបង្កើតនូវប្រព័ន្ធផ្ទេរមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌដ៏មានប្រសិទ្ធភាពមួយ។

ការរៀបចំជាបន្ទាន់នូវយន្តការដើម្បីផ្ទេរធនធានគ្មានភ្ជាប់លក្ខខណ្ឌពីថវិការដ្ឋឱ្យដល់ក្រុង ស្រុក សម្រាប់ការអភិវឌ្ឍដល់រដ្ឋបាលក្រុង ស្រុក តាមរយៈការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តិនានា ស្តីពីប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុ និងការបង្កើតមូលនិធិរបស់ថ្នាក់រដ្ឋបាលនេះ ដូចដែលបានកំណត់ក្នុងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនឹងដោះស្រាយបាននូវបញ្ហាប្រឈមនានា ដែលកំពុងលេចចេញឡើងនៅក្នុងការដ្ឋាននៃកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានជាអាទិ៍÷

- ***បញ្ហាប្រឈមផ្នែកនយោបាយៈ***

ក្រុមប្រឹក្សា និងរចនាសម្ព័ន្ធរបស់ក្រុង ស្រុក ត្រូវបានបង្កើត និងចូលកាន់មុខតំណែងរបស់ខ្លួនអស់រយៈពេលជាង២ឆ្នាំកន្លងមកហើយជាមួយនឹងការគ្មានធនធានសម្រាប់រៀបចំជាផែនការអភិវឌ្ឍន៍ និងប្រើប្រាស់ក្រោមសិទ្ធិសម្រេចចិត្តរបស់ខ្លួនដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលខ្លួនត្រូវមានគណនេយ្យភាពជាមួយជាបឋម។ ការទុកឱ្យស្ថានភាពនេះបន្តកើតឡើងទៅមុខទៀតនឹងកាន់តែធ្វើឱ្យរដ្ឋបាលថ្នាក់នេះពុំអាចពង្រឹងការទទួលខុសត្រូវរបស់ខ្លួន និងបាត់បង់នូវជំនឿទុកចិត្តពីប្រជាពលរដ្ឋដែលនឹងជះឥទ្ធិពលជាអវិជ្ជមានដល់កិត្យានុភាពរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះដែរ ក្រុមប្រឹក្សាទាំងនេះក៏កំពុងទទួលបាននូវការបណ្តុះបណ្តាលជាបន្តបន្ទាប់ដែលអនុញ្ញាតឱ្យក្រុមប្រឹក្សាកាន់តែយល់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ដែលប្រការនេះបានធ្វើមានប្រតិកម្មដែល គ.ជ.អ.ប មិនអាចដោះស្រាយបានទាក់ទងទៅនឹងអាណត្តិរបស់ក្រុមប្រឹក្សាដោយសារតែ

មកដល់ពេលនេះរដ្ឋបាលរបស់ខ្លួនពុំមានធនធានសម្រាប់អនុវត្តមុខងារជាជម្រើស ទោះបីក្នុងកម្រិតណាមួយសម្រាប់កិច្ចប្រតិបត្តិការ (ក្រៅពីប្រាក់បៀវត្សរ៍) និងការអភិវឌ្ឍមូលដ្ឋាន។

- ***បញ្ហាប្រឈមពាក់ព័ន្ធនឹងការកសាងប្រព័ន្ធ ការកសាងសមត្ថភាព និងការអនុវត្តមុខងារដែលត្រូវផ្ទេរ:***

ប្រព័ន្ធសំខាន់ៗមួយចំនួនសម្រាប់អភិបាលកិច្ច និងអភិវឌ្ឍក្រុង ស្រុកត្រូវបានរៀបចំ រួមជាមួយនឹងកម្មវិធីអភិវឌ្ឍសមត្ថភាពជាបណ្តើរៗដើម្បីប្រតិបត្តិការប្រព័ន្ធទាំងនោះ។ ក្នុងខណៈដែលមិនមានធនធានសមស្របសម្រាប់ប្រតិបត្តិប្រព័ន្ធទាំងនោះ ការអភិវឌ្ឍសមត្ថភាពនឹងមិនអាចមានប្រសិទ្ធភាពបានឡើយ។ ក្នុងស្ថានភាពបែបនេះ រដ្ឋបាលក្រុង ស្រុកនឹងមិនត្រឹមតែគ្មានសមត្ថភាពក្នុងការអនុវត្តមុខងារជាជម្រើសរបស់ខ្លួននោះឡើយ ថែមទាំងនៅតែមិនមានសមត្ថភាពសម្រាប់អនុវត្តមុខងារជាកាតព្វកិច្ចនានាដែលថ្នាក់ជាតិនឹងផ្ទេរឱ្យនាពេលអនាគតថែមទៀតផង។

- ***បញ្ហាប្រឈមពាក់ព័ន្ធនឹងការកៀរគរធនធានគាំទ្រពីដៃគូអភិវឌ្ឍន៍:***

ដៃគូអភិវឌ្ឍសំខាន់ៗមួយចំនួនបានបង្ហាញនូវឆន្ទៈគាំទ្រយ៉ាងខ្លាំងលើការពង្រឹងរដ្ឋបាលក្រុង ស្រុកដែលជាថ្នាក់រដ្ឋបាលមានទីតាំងដ៏សំខាន់ក្នុងការធ្វើសហប្រតិបត្តិការជាមួយឃុំ សង្កាត់ ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍមូលដ្ឋានដូចដែលបានកំណត់ក្នុងផអ៣។ ជាក់ស្តែង រដ្ឋាភិបាលស៊ុយអែត តាមរយៈកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន ដែលទើបបានចុះហត្ថលេខាថ្មីៗនេះ បានផ្តល់មូលនិធិប្រមាណ៤លានដុល្លារអាមេរិក សម្រាប់គាំទ្រដល់គម្រោងវិនិយោគក្រុង ស្រុកដែលមូលនិធិនេះត្រូវប្រើប្រាស់ប្រព័ន្ធមូលនិធិក្រុង ស្រុក។ មូលនិធិនេះ ត្រូវបានកំណត់ឱ្យប្រើប្រាស់ក្នុងរយៈពេល ១៩ខែ គឺពីខែមេសា ឆ្នាំ២០១១ ដល់ខែកញ្ញា ឆ្នាំ២០១២។ ភាពយឺតយ៉ាវក្នុងការដាក់ឱ្យអនុវត្តមូលនិធិក្រុង ស្រុក មិនត្រឹមតែប៉ះពាល់ដល់មូលនិធិគាំទ្រនេះប៉ុណ្ណោះឡើយ ប៉ុន្តែក៏អាចប៉ះពាល់ដល់ការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀតមកលើឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងដំណើរការកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

- ***បញ្ហាប្រឈមពាក់ព័ន្ធនឹងការចំណាយផ្នែករដ្ឋបាល:***

មកទល់បច្ចុប្បន្ននេះ ថវិការបស់ក្រុង ស្រុកស្ថិតជាផ្នែកមួយនៃកញ្ចប់ថវិការបស់ខេត្ត។ តាមការចុះសិក្សាស្រាវជ្រាវជាបន្តបន្ទាប់របស់ក្រុមការងាររួមនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃបានបង្ហាញឱ្យឃើញថា ក្រៅពីប្រាក់បៀវត្សរ៍ក្រុង ស្រុកភាគច្រើនបានទទួលថវិកាសម្រាប់គ្រាន់តែបម្រើកិច្ចការរដ្ឋបាលដ៏តិចតួចបំផុត ដែលពុំអាចធានាបាននូវកិច្ចការរដ្ឋបាលដ៏មានប្រសិទ្ធភាពនោះឡើយ។ ក្នុងឆ្នាំ ២០១១នេះ រដ្ឋបានចំណាយថវិកាប្រមាណ ១១ លានដុល្លារអាមេរិកសម្រាប់ប្រាក់ឧបត្ថម្ភ និងប្រាក់បៀវត្សរ៍របស់ក្រុមប្រឹក្សា និងមន្ត្រីរដ្ឋបាលក្រុង ស្រុកនៅទូទាំងប្រទេស (ក្រុមប្រឹក្សាស្រុក ក្រុងមានចំនួន ៣៩៥៤នាក់ និងមន្ត្រីរដ្ឋបាលក្រុង ស្រុកជាង៣០០០នាក់)។ ក្រៅពីនេះ រដ្ឋក៏បានចំណាយទៅលើប្រាក់បៀវត្សរ៍របស់មន្ត្រីការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ដែលមានចំនួនសរុបប្រមាណជាង១០.០០០នាក់ ក្នុងពេលដែលការិយាល័យជំនាញភាគច្រើន ស្ទើរពុំដែលទទួលបាននូវការបែងចែកថវិកាសម្រាប់បំពេញមុខងារពីក្រសួង ស្ថាប័នរបស់ខ្លួន។

ការចំណាយទៅលើផ្នែករដ្ឋបាលដ៏ធំធេងដូចបានរៀបរាប់ខាងលើ និងការប្រើប្រាស់មន្ត្រីនយោបាយ និងមន្ត្រីមុខងារសាធារណៈសរុបប្រមាណ១៦.០០០នាក់ សម្រាប់ប្រព័ន្ធរដ្ឋបាលនៅថ្នាក់ក្រុងស្រុកនេះ គប្បីត្រូវបានពិនិត្យមើលឡើងវិញអំពីផលប៉ះពាល់ និងគុណប្រយោជន៍ដែលបានមកពីការចំណាយនេះ ក្នុងពេលដែលថ្នាក់រដ្ឋបាលដ៏សំខាន់នេះពុំបានទទួលការផ្តល់នូវធនធានសម្រាប់កិច្ចការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។

ពាក់ព័ន្ធនឹងស្ថានភាពដ៏គួរឱ្យព្រួយបារម្ភនេះ និងដោយសារការរៀបចំបង្កើតនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងយន្តការផ្ទេរធនធានគ្មានភ្ជាប់លក្ខខណ្ឌពីថវិកាជាតិ ដើម្បីវិភាជធនធានថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការអនុវត្តអនុកម្មវិធីទី៤នៃផ.អ៣ គឺជាតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាស្រ័យហេតុនេះ ក្នុងនាមក្រសួងមហាផ្ទៃ និង គ.ជ.អ.ប ខ្ញុំសូមស្នើឯកឧត្តមមេត្តា ជួយជំរុញដល់ការរៀបចំនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ការបង្កើត និងវិធានអនុវត្តរបស់មូលនិធិក្រុង ស្រុក និងកំណត់ការចូលរួមចំណែកពីថវិកាជាតិទៅក្នុងមូលនិធិនេះក្នុងទំហំដ៏សមស្របជាបឋមមួយសម្រាប់ថ្នាក់ក្រុង ស្រុក ដើម្បីមានលទ្ធភាពប្រើប្រាស់ថវិកាហិរញ្ញប្បទានរបស់ស៊ុយអែតចំនួន៤លានដុល្លារអាមេរិកសម្រាប់ឆ្នាំ២០១១នេះ និងធានាបាននូវការចាប់ផ្តើមវិភាជថវិកាជាតិជាកញ្ចប់មូលនិធិសម្រាប់រដ្ឋបាលស្រុក ក្រុង ចាប់ពីឆ្នាំ២០១២តទៅទៀត។ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងខិតខំផ្តល់កិច្ចសហការផ្នែកជំនួយបច្ចេកទេសលើបញ្ហានេះបន្ថែមទៅលើការគាំទ្រថវិកាដែលបានវិភាជន៍ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចហើយក្នុងការអនុវត្តអនុកម្មវិធីទី៤របស់ផអ៣។

លេខាធិការដ្ឋាន គ.ជ.អ.ប បានស្នើនូវរបៀបវារៈនៃកិច្ចប្រជុំ គ.ជ.អ.ប ដោយស្នើសុំឱ្យ គ.ជ.អ.ប ធ្វើការពិភាក្សា និងផ្តល់ការណែនាំអំពីគោលនយោបាយបន្ថែមទៀតពីបញ្ហានេះ។ ខ្ញុំសង្ឃឹមថា យើងនឹងបានពិភាក្សាយ៉ាងលម្អិត និងទទួលបាននូវការឯកភាពជាគោលការណ៍ទៅលើសំណើរបៀបវារៈនៃបញ្ហានេះនៅក្នុងកិច្ចប្រជុំរបស់ គ.ជ.អ.ប ដែលគ្រោងនឹងរៀបចំនាពេលឆាប់ៗខាងមុខនេះ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប**

**ស ខេង**

__ចម្លងជូន__

- ក្រសួង ស្ថាប័នក្នុង គ.ជ.អ.ប
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ